**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤០៥
ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០
<u>សាលដីកា</u>
លេខ:១៧៧
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............. ជាចៅក្រមរបាយការណ៍
៣-លោក .............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក .............

**<u>តំណាងមហាអយ្យការ</u>**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ២៦(គ) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៩២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះមស (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៦៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ មានទីលំនៅបច្ចុប្បន្ន ភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះម៉ាត់ (ស) ម្តាយឈ្មោះទី រៀម (ស) ប្រពន្ធឈ្មោះពិត មានកូន០៦នាក់ ។

មានមេធាវីអ្នកស្រី ...........។ ។

ចុងចម្លើយឈ្មោះទង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើចំការ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះទូច(ស) ម្តាយឈ្មោះធួ ទីម (ស) ប្តីឈ្មោះផាន់ មានកូន០២នាក់ ។

កម្មវត្ថុបណ្តឹង: ប្តឹងសុំសិទ្ធិគ្រប់គ្រងដី១៣ម x ១៤៧ម .

បានឃើញបណ្តឹងសាទុក្ខលេខ២៣៩ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះទង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៦(គ)ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤០៥ចុះថ្ងៃទី១៦ខែតុលាឆ្នាំ២០០០របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៧-១២-៩៨ របស់ដើមចោទឈ្មោះមស បានប្តឹងទាមទារដីទំហំ១៣មx ១៤៧ម ពីឈ្មោះទង .ដោយសំអាងហេតុថា ដីនេះខ្លួនគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ ព្រមទាំងបានដាំដំណាំចេក ស្វាយ នៅលើដីនោះទៀតផង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៨៣(ក) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះមស ចុះថ្ងៃទី១៧-១២-៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២-ទទួលស្គាល់សិទ្ធិរបស់ដើមចោទឈ្មោះមស ជាម្ចាស់កម្មសិទ្ធិលើដីកើតហេតុ តាមគំនូសប្លង់របស់ភូមិបាលស្រុកកំពង់សៀមចុះថ្ងៃទី០៣-០៦-៩៩ ចាប់ពីពេលដែលសាលក្រម នេះចូលជាស្ថាពរ (តាមមាត្រា២ នៃច្បាប់ភូមិបាល) ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧០០០៛ ដែលដើមចោទបានបង់រួចហើយ ។

ពេលសាលក្រមចូលស្ថាពរបង្គាប់ឱ្យចុងចម្លើយបង់សងវិញ និងឱ្យចុងចម្លើយបង់ពន្ធសមាមាត្រមួយ ភាគរយ លើប្រាក់តម្លៃដី ។ ត្រូវជាប្រាក់១០.០០០៛(មួយម៉ឺនរៀលគត់) ប្រាក់ពន្ធនេះត្រូវឱ្យដើមចោទបង់ទុកជាមុន ទើបបង្គាប់ឱ្យចុងចម្លើយបង់សងវិញជាក្រោយ ។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ។ បើភាគីណាមិនសុខចិត្ត និងសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់ឈ្មោះទង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៨៣(ក) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៦(គ) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៤៥ ចុះថ្ងៃទី១៦កក្កដា១៩៩៩ របស់ឈ្មោះទង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៨៣(ក) ចុះថ្ងៃទី១៥ កក្កដា ១៩៩៩ របស់តុលាការ ខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី១៣.០០០៛ ដែលឈ្មោះទង បានបង់រួចហើយគឺ:

ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹង សាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៣៩ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះទង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៦(គ)ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះទង ។

បានឃើញសារណាតប ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះមស ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈសាលដីកាសាលាឧទ្ធរណ៍ បានសម្រេចខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះទង នាពេលសវនាការថា : ខ្លួនសូមឱ្យកូនឆ្លើយជំនួសខ្លួនចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសយ វណ្ណា នាពេលសវនាការថា : ខ្លួនជាកូនបង្កើតរបស់ទង ដីនេះម្តាយខ្លួននៅតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ពេលចុះវាស់វែង ខ្លួនវាស់ជាមួយគេដែរ ហើយមុនឆ្នាំ១៩៧៩ម្តាយខ្លួនរស់នៅលើដីនេះដែរ ដីនេះមានរដ្ឋអំណាចភូមិ-ឃុំ-ស្រុក ប្រគល់ឱ្យម្តាយខ្លួន ឯងដំណាំមានចេកក្រូចស្វាយ. ម្តាយខ្លួនទទួលផលរហូតសព្វថ្ងៃ ។

បានស្តាប់ចម្លើយរបស់ឈ្មោះមស នាពេលសវនាការថាៈ ដីទំនាស់នេះនៅពីក្រោយ ដីរបស់ដើមចោទ ដីនេះខ្លួនបានកាន់កាប់គ្រប់គ្រងពីឆ្នាំ១៩៧៩មក ហើយមុន១៩៧៩ ជាដីកេរ្តិ៍របស់ ខ្លួនដែរ ក្រោយឆ្នាំ១៩៧៩ ខ្លួនបានចូលកាន់កាប់ដីនេះ ហើយដាំដំណាំ និងបេះផ្លែស្វាយផង តែដល់ឆ្នាំ១៩៨០ ឈ្មោះទង កាប់បំផ្លាញចេកខ្លួន ពេលគាត់ដាំចេកថ្មី ហើយមិនឱ្យខ្លួនចូលប៉ះពាល់ ដល់ឆ្នាំ១៩៩៨ ទើបខ្លួនប្តឹងតែម្តង។សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការតទៅ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី...........។ ជាមេធាវីការពារឱ្យដើមចោទបានលើក ឡើងថាកូនក្តីខ្លួនបានរស់នៅ និងអាស្រ័យផលលើដីទំនាស់នេះ តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយតុលាការថ្នាក់ក្រោម ក៏ដូចជាសាលាឧទ្ធរណ៍ដែរ បានសម្រេចប្រគល់ដីទំនាស់នេះឱ្យមកកូនក្តី ខ្លួន ដូចនេះ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍.

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣៩ ចុះថ្ងៃទី០២-០៦-២០០០ របស់អ្នកស្រីទង ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ និងតុលាការខេត្តកំពង់ចាម សម្រេចប្រគល់ដី ទំនាស់ទំហំ៩០៦ម² ឱ្យដើមចោទជាកម្មសិទ្ធិដោយអាងហេតុលើសាក្សីដើមចោទ និងរបាយការណ៍ចុះថ្ងៃទី០៣-០៣-១៩៩៩ របស់ជំទប់ទី១ ឃុំគគរ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា:

នៅពេលសវនាការនេះ ដើមចោទបានលើកឡើងថា ដីទំនាស់នេះជាដីកេរ្តិ៍ របស់លោកមុនឆ្នាំ១៩៧៩ លោកចូលកាន់កាប់ដាំដុះ និងអាស្រ័យផល ។ លុះដល់ឆ្នាំ១៩៨០ ចុងចម្លើយបានកាប់របងនិងដំណាំចេញ រួចគ្រប់គ្រងរហូតមក លោកពុំបានគ្រប់គ្រងទេ ដោយចុងចម្លើយរាំងរហូតដល់ឆ្នាំ១៩៩៨ ទើបលោកប្តឹង ។

ដីទំនាស់នេះ ស្ថិតនៅចំពីក្រោយ និងជាប់នឹងដីលំនៅដ្ឋានចុងចម្លើយ ហើយ តាមរបាយការណ៍លេខ៦១-៩៩ ភប.កស ចុះថ្ងៃទី០៩-០៦-១៩៩៩ របស់ការិយាល័យភូមិបាលស្រុកកំពង់សៀមបញ្ជាក់ថា ទាំងដើមចោទ និងចុងចម្លើយអាស្រ័យផលដំណាំស្វាយលើដីទំនាស់ដូចគ្នានាំឱ្យមានការប្រទាញប្រទង់គ្នា ។ ដូច្នេះយ៉ាងហោចណាស់ ក៏តុលាការគប្បីពិចារណាដល់សិទ្ធិរបស់ភាគីទាំងពីរលើដីទំនាស់តាមរបាយការណ៍របស់ការិយាល័យភូមិបាលស្រុកកំពង់សៀមដែរ ។

- យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចសេចក្តី តម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ចាម មានលក្ខណៈខុសឆ្គងទាំងទំម្រង់ និងគតិច្បាប់ហើយ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ២៣៩ ចុះថ្ងៃទី០២-០៦-២០០០ របស់អ្នកស្រីទង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៦(ធ) ចុះថ្ងៃទី២៥-០៥-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤០៥ ចុះថ្ងៃទី១៦-១០-២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលចុងចម្លើយ បានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០៛ គឺ:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០រៀល ហើយតម្រូវឱ្យដើមចោទសងប្រាក់ ១៩.០០០រៀល នេះ ទៅចុងចម្លើយវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ។